# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២ សសរ

## សេចក្តីសម្រេច

## ស្តីពីការកែសម្រួលសេចក្តីសម្រេចស្តីពីការកែសម្រួលសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារតាមវិស័យសម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣ / នស / ៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស / រកម / ០៣០៣ / ០០៩ ចុះ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសេចក្តីជូនដំណឹងលេខ ១១៦៩ សជណ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៦ ស្តីពីលទ្ធផលនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី ១០ នាថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៦
- យោងសេចក្តីសម្រេចលេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារតាមវិស័យ សម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន និងសេចក្តីសម្រេចកែសម្រួលលេខ ៣៧ សសរ ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៦

www.pheakdeylaw.com

- យោងសេចក្តីសម្រេចលេខ ៤៦ សសរ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ របស់រាជរដ្ឋាភិបាលស្តីពី ការបង្កើតអនុគណៈកម្មការដឹកនាំការងារ ដើម្បីអភិវឌ្ឍផ្នែកឯកជន និងសេចក្តីសម្រេចកែសម្រួល លេខ ៣២ សសរ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥
- យោងសេចក្តីសម្រេចលេខ ០៤ សសរ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលស្តីពី ការកែសម្រួលសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារតាមវិស័យ សម្រាប់ធ្វើជាដៃគូពិភាក្សាការងារ ជាមួយផ្នែកឯកជន
- យោងតាមតម្រូវចាំបាច់

## ស ម្រេ ច

**ប្រការ ១** : កែសម្រួលឈ្មោះរបស់អនុគណៈកម្មាធិការកិច្ចសម្រួលពាណិជ្ជកម្ម ដែលមានចែងក្នុងចំណុច ខ ប្រការ ១ នៃសេចក្តីសម្រេចលេខ ៤៦ សសរ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ និងចំណុច ខ ប្រការ ៣ នៃ សេចក្តីសម្រេចលេខ ០៤ សសរ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៧ មកជាអនុគណៈកម្មាធិការអភិវឌ្ឍ ពាណិជ្ជកម្ម និងវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម ។

**ប្រការ ២** : អនុគណៈកម្មាធិការអភិវឌ្ឍពាណិជ្ជកម្ម និងវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម មានភារកិច្ច ដូចខាងក្រោម :

- ទទួលបន្ទុកការងារលើគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍ និងប្រតិបត្តិនយោបាយពាណិជ្ជកម្ម នៃ រាជរដ្ឋាភិបាល និងជាចំណុចប្រសព្វ សម្រាប់ពិភាក្សារវាងរដ្ឋាភិបាលជាមួយនឹងដៃគូអភិវឌ្ឍន៍ ព្រមទាំងវិស័យឯកជន អំពីនយោបាយពាណិជ្ជកម្ម ។
- សម្របសម្រួលសកម្មភាព និងផែនការការងារទាំងអស់ ដែលប្រតិបត្តិដោយអនុគណៈកម្មាធិការ សម្រួលពាណិជ្ជកម្ម និងក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញ និងកិច្ចសម្រួល ពាណិជ្ជកម្ម បានធ្វើកន្លងមក ។
- ក្រុមការងារផ្នែកផលិតកម្ម កែច្នៃសម្រាប់នាំចេញ នៅតែបន្តកម្មវិធីការងារ និងរបប រាយការណ៍របស់ខ្លួនដដែល តែត្រូវធ្វើរបាយការណ៍មកអនុគណៈកម្មាធិការអភិវឌ្ឍពាណិជ្ជកម្ម និងវិនិយោគ ទាក់ទងនឹងពាណិជ្ជកម្ម និងទទួលការណែនាំពីអនុគណៈកម្មាធិការនេះ ។

ភារកិច្ចដែលមានចែងនៅក្នុងចំណុច ខ ប្រការ ២ នៃសេចក្តីសម្រេចលេខ ៤៦ សសរ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ ត្រូវបានជំនួសដោយភារកិច្ច ដូចខាងក្រោម :

www.pheakdeylaw.com

## អនុគណៈកម្មាធិការអភិវឌ្ឍពាណិជ្ជកម្ម និងវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម

### ១- ភារកិច្ចទូទៅ

- ពិចារណាលើនូវរាល់បញ្ហាដែលទាក់ទងនឹងការអភិវឌ្ឍ និងនយោបាយពាណិជ្ជកម្ម ការសម្របសម្រួលនយោបាយពាណិជ្ជកម្ម ការគាំទ្រដោយដៃគូអភិវឌ្ឍន៍ និងការចូលរួមអភិវឌ្ឍវិស័យឯកជន។
- ពិនិត្យផែនការសកម្មភាពក្នុងវិស័យពាណិជ្ជកម្ម ជាផែនការសកម្មភាព ដែលមានចែងនៅក្នុងដំណើរការក្របខ័ណ្ឌសមាហរណកម្ម។
- ទទួលរបាយការណ៍អំពីការអនុវត្ត ការតាមដាន និងការធ្វើបច្ចុប្បន្នភាព នៃផែនការសកម្មភាពទាំងនោះ ព្រមទាំងផ្តល់អនុសាសន៍លើរបាយការណ៍។
- ពង្រឹងការពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ អំពីជំនួយទាក់ទងនឹងពាណិជ្ជកម្ម។ កៀរគរជំនួយដែលត្រូវការ ដូចមានក្នុងផែនការសកម្មភាព និងលើកកម្ពស់ការសម្របសម្រួលជំនួយទាំងនោះ។
- ពង្រឹងការពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និងសហគមន៍ធុរៈកិច្ច អំពីបញ្ហាពាណិជ្ជកម្ម។

### ២- ភារកិច្ចទាក់ទងនឹងកិច្ចសម្រួលពាណិជ្ជកម្ម

- កាត់បន្ថយដំណើរការ និងបែបបទស្មុគស្មាញ និងវែងអន្លាយ តាមក្រសួង និងស្ថាប័ន ដែលទាក់ទងនឹងការនាំចេញ-នាំចូល របស់បណ្តាក្រុមហ៊ុន។
- លុបបំបាត់ភារកិច្ចជាន់គ្នា រវាងក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ដើម្បីអនុវត្តការត្រួតពិនិត្យតែម្តងរួមគ្នា ប្រកបដោយប្រសិទ្ធភាព។
- ពង្រឹងយន្តការច្រកចេញ-ចូលតែមួយ នៅតាមបណ្តាមាត់ច្រកអន្តរជាតិ។
- ដាក់ចេញនូវវិធានការចាំបាច់ សំដៅអនុវត្តច្បាប់ និងបទប្បញ្ញត្តិ ដើម្បីដោះស្រាយឧបសគ្គដែលទាក់ទងដល់សកម្មភាពពាណិជ្ជកម្ម។

### ៣- ភារកិច្ចជាអង្គភាពគាំទ្រ

ទទួលរបាយការណ៍ និងផ្តល់អនុសាសន៍ដល់ក្រុមការងារ និងគណៈកម្មាធិការ ដូចខាងក្រោម ៖

- គណៈកម្មាធិការអន្តរក្រសួង សម្រាប់អនុវត្តកាតព្វកិច្ចអង្គការពាណិជ្ជកម្មពិភពលោក គណៈកម្មាធិការជាតិកូដិច (Codex) គណៈកម្មាធិការគ្រប់គ្រងកម្មសិទ្ធិបញ្ញា ក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញ និងកិច្ចសម្រួលពាណិជ្ជកម្ម។
- បង្កើតក្រុមការងារពិសេស សម្រាប់កិច្ចសម្រួលពាណិជ្ជកម្ម (Task Force for Trade Facilitation)។

www.pheakdeylaw.com

- បង្កើតក្រុមការងារពិសេសផ្សេងៗទៀត ក្នុងវិស័យពាណិជ្ជកម្មទៅតាមការចាំបាច់ ។

## ៤- ភារកិច្ចស្តីពីកិច្ចសហការជាមួយអង្គភាពផ្សេង

- ធ្វើសហប្រតិបត្តិការជិតស្និតជាមួយបណ្តាអង្គភាពដែលពាក់ព័ន្ធ រួមមានអនុគណៈកម្មាធិការបរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជន ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ អនុគណៈកម្មាធិការផ្នែកកម្មន្តសាល និងសហគ្រាសតូច-មធ្យម ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្ម និងជនបទ គណៈកម្មាធិការអន្តរក្រសួងអំពីការនាំចេញកសិផល វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ។
- អញ្ជើញតំណាងអង្គភាពខាងលើ ដើម្បីចូលរួមក្នុងកិច្ចប្រជុំ នៃអនុគណៈកម្មាធិការអភិវឌ្ឍពាណិជ្ជកម្ម និងវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម ក្នុងករណីដែលរបៀបវារៈ នៃកិច្ចប្រជុំមានការពាក់ព័ន្ធ ។
- ជូនដំណឹងជាប្រចាំដល់អង្គភាពទាំងនោះ អំពីលទ្ធផលនៃកិច្ចប្រជុំ ។
- អញ្ជើញអង្គភាពពាក់ព័ន្ធផ្សេងទៀត ចូលរួមកិច្ចប្រជុំរបស់ខ្លួន ។
- អញ្ជើញអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធ មកចូលរួមប្រជុំតាមសិទ្ធិអំណាចរបស់ប្រធាន ។

**ប្រការ ៣** : ក្រៅពីការកែសម្រួល ដូចមានក្នុងប្រការ ១ និងប្រការ ២ នៃសេចក្តីសម្រេចលេខ ៤៦ សសរ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ និងប្រការ ៣ នៃសេចក្តីសម្រេចលេខ ០៤ សសរ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៧ សេចក្តីសម្រេចលេខ ៤៦ សសរ និងសេចក្តីសម្រេចលេខ ០៤ សសរ នៅមានសុពលភាពដដែល ។

**ប្រការ ៤** : ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន អភិបាលខេត្ត-ក្រុង និងសមាសភាពដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែ មីនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៤ " ដើម្បីអនុវត្ត "*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com